# ទិដ្ឋាការចេញចូលមួយដង គោលបំណងទៅលេងមិត្តភក្តិ

សម្រាប់សាមីជនដែលមានបំណងទៅលេងមិត្តភក្តិ ឬសាច់ញាតិខ្មែរឆ្ងាយដែលកំពុងស្នាក់នៅប្រទេសជប៉ុនសូមរៀបចំឯកសារដូចខាងក្រោម។

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ឯកសារត្រូវរៀបចំដោយសាមីជន | | | |
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ *ច្បាប់ដើម*<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | · កំណត់ត្រាដែលបង្ហាញពីទំនាក់ទទង ដូចជារូបថតអ៊ីម៉ែល, SNS។ល។ |
| ៤ | ☐ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · ករណីសាមីជនជាអ្នកចំណាយដោយខ្លួនឯងសេចក្តីចម្លងគុណបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ)<br>មិនមែន BANK CONFIRMATION. |
| ឯកសារត្រូវរៀបចំដោយភាគីអញ្ជើញខាងជប៉ុន (ច្បាប់ដើម ឬចម្លង) | | | |
| ៥ | ☐ | លិខិតបញ្ជាក់មូលហេតុនៃការអញ្ជើញ | · មិនតម្រូវអោយមានត្រាទេ<br>· សូមពន្យល់ពី "គោលបំណងអញ្ជើញ" និង "ដើមហេតុនៃការអញ្ជើញ"អោយបានក្បោះក្បាយ។<br>· ករណីអញ្ជើញច្រើនជាងម្នាក់ សូមសរសេរ "ចំនួនបន្ថែមនៅលើលិខិតអញ្ជើញនេះ" និងភ្ជាប់ "បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ"។ |
| ៦ | ☐ | លិខិតបញ្ជាក់ទីលំនៅ<br>(Jyuminhyo) | · មានបញ្ជាក់ទាំងសមាជិកដែលរស់នៅជាមួយ (បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ) |

| | | | |
|---|---|---|---|
| ៧ | □ | តារាងស្នាក់នៅ | · សរសេរលម្អិតពីសកម្មភាពប្រចាំថ្ងៃ (ចាប់ពីថ្ងៃចូលរហូតដល់ចេញពីប្រទេសជប៉ុន)<br>· គម្រោងថ្ងៃចូលនិង ចេញពីជប៉ុន, ជើងហោះហើរដែលអ្នកគ្រោងជិះ, ឈ្មោះព្រលានសម្រាប់ហោះចូល និងចេញពីប្រទេសជប៉ុន។<br>· បំពេញពត៌មានកន្លែងស្នាក់/សណ្ឋាគារ (ឈ្មោះ, អាស័យដ្ឋាន, លេខទូរស័ព្ទ) |
| ៨ | □ | (ករណីអ្នកអញ្ជើញមិនមានសញ្ជាតិជប៉ុន) កាតស្នាក់នៅ និង លិខិតបញ្ជាក់ទីលំនៅ | · ច្បាប់ចម្លង(សងខាង)កាតស្នាក់នៅដែលមានសពុលភាព ឬលិខិតបញ្ជាក់ការស្នាក់នៅអចិន្ត្រៃយ៍ពិសេស<br>· ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ“Jyuminhyo” (បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ)។ មានបង្ហាញពត៌មានទាំងអស់ដែលបានរាយបញ្ជី លើកលែងតែលេខសម្គាល់បុគ្គល “My Number” និងលេខកូដកំណត់ត្រាស្នាក់នៅ។ |
| ឯកសារត្រូវរៀបចំដោយភាគីធានានៅជប៉ុន(ករណីខាងជប៉ុនចេញថ្លៃចំណាយ) (ច្បាប់ដើម ឬចម្លង) | | | |
| ៩ | □ | លិខិតធានា | · មិនតម្រូវអោយមានត្រាទេ<br>· ករណីធានាច្រើនជាងម្នាក់ សូមសរសេរ ‟ចំនួនបន្ថែមនៅលើលិខិតធានានេះ″ និងភ្ជាប់ ‟បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ″។ |
| ១០ | □ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · ដាក់ឯកសារមួយក្នុងចំណោមឯកសារខាងក្រោម<br>- លិខិតបញ្ជាក់ប្រាក់ចំណូល/ការបង់ពន្ធចុងក្រោយបំផុត (ធ្វើដោយសាលាភូមិ ឃុំ សង្កាត់ ខណ្ឌ)។<br>-លិខិតបញ្ជាក់ការបង់ពន្ធ(ទម្រង់២, ធ្វើដោយការិយាល័យពន្ធដារ)។<br>- សេចក្តីចម្លងតុល្យបញ្ជីគណនី (ធ្វើដោយធនាគារ)<br>- វិញ្ញាបនបត្រនៃប័ណ្ណប្រកាសពន្ធ (មានត្រាទទួលរបស់ការិយាល័យពន្ធដារ) ។<br>* សម្រាប់ពន្ធអេឡិចត្រូនិកៈ ដាក់‟បង្កាន់ដៃការជូនដំណឹង″ និង ‟ការបង់ពន្ធចុងក្រោយ″ ។ |